ញ៉ុក . ថែម

# មហាវេស្សន្តរជាតក



## កណ្ឌទី ១០

ផ្សាយឡើងវិញ "[illegible]"
រក្សាសិទ្ធិគ្រប់យ៉ាង
ព.ស ២៥៤៦ គ.ស ២០០២

# មហាវេស្សន្តរជាតក

## ទី ១០

## **កណ្ហាសក្កបព្វ**

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឯវន្តេសុ អញ្ញមញ្ញំ សម្មោទនីយំ កថំ កថេន្តេសុ សក្កោ ទេវរាជា ចិន្តេសិ អយំ វេស្សន្តរមហារាជា ហិយ្យោ ជូជកស្ស បឋវឹ ឧន្នាទេត្វា ទារកេ អទាសិ ឥទានិ នំ កោចិ ហីនបុរិសោ ឧបសង្កមិត្វា សព្វលក្ខណសម្បន្នំ សីលវតឹ មទ្ទឹ យាចិត្វា រាជានំ ឯកកំ កត្វា មទ្ទឹ គហេត្វា គច្ឆេយ្យ តតោ ឯស អនាថោ និប្បច្ចយោ ភវេយ្យ យន្នូនាហំ ព្រាហ្មណវណ្ណេន នំ ឧបសង្កមិត្វា មទ្ទឹ យាចិត្វា ចារមិកូដំ គាហាបេត្វា កស្សចិ អវិសជ្ជនីយំ កត្វា បុន តំ តស្សេវ ទត្វា អាគមិស្សាមីតិ ។

តេសុ ខត្តិយេសុ នាកាលព្រះបរមពោធិសត្វ ខត្តិយនរេស្សរ៍ ព្រះវេស្សន្តរបវរពុទ្ធវង្ស ទ្រង់ព្រះរាជសទ្ធាទាំងសម្តេចព្រះជាយានារី

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្រីសុន្ទរបវរក្សត្រី **សម្ភោគនីយំ** ទាំងពីរព្រះអង្គ ទ្រង់ព្រះសោមនស្សាភិរម្យ សន្សំព្រះបិយបុត្តទាន ទ្រង់ក្សេមក្សាន្តព្រះរាជហឫទ័យ នៅព្វដ៏ព្រៃគន្ធមាទន៍ **សត្តោ** ទើបសម្ដេចព្រះអម្រិន្ទ្រឥន្ទកោសិយ ទ្រង់នឹកក្នុងកំឡុងព្រះរាជហឫទ័យ ដើម្បីជាប្រយោជន៍ នៃព្រះបរមពោធិសត្វ អ្នកនឹងបានត្រាស់សម្មាសម្ពោធិញ្ញាណ **ហិយ្យោ** នាថ្ងៃអម្បិលមិញនោះ ព្រះអង្គព្រះរាជទានព្រះរាជបុត្រាបុត្រី លើកយកព្រះបរមត្ថបារមី ដ៏ជាមកុដនៃទាន ឱ្យទៅជូជកជាអ្នកកំសត់អត់ឃ្លាន លំបាកថ្មើរព្រៃ ដ៏ជាមហែមហាឧឡារិកពេកក្រៃ នៅតែវរវត្នរាជកញ្ញាមទ្រីមហេសី ។ អើបើអញនឹងស្ងៀមនៅ យល់ជាបង់សេចក្ដីពុំខាន ក្រែងមានអ្នកជូជាតិថយសក្តិ នឹងមកកាន់សំណាក់សុំព្រះអគ្គមហេសី ព្រះអង្គក៏នឹងលើកយកព្រះមទ្រីឱ្យទៅជាទាន ត្បិតទ្រង់ពុំដែលមានព្រះរាជហឫទ័យរួញរាឡើយ ។ ឱះ ឱអនិច្ចាអើយ សមនឹងសាបសូន្យព្រះវង្ស ដ៏ជាមង្គលក្សត្រី ឥតបីអ្នកនឹងប្រណិប័តន៍ឧបដ្ឋាក ក៏នឹងរំលៀងចេញចាកវត្តចរិយា ព្រះអង្គចម្រើនមេត្តាក៏នឹងសង្វេគព្រះទ័យអង្គឯងវែងជាអាងខ្មាងនៅក្នុងព្រៃព្រឹក្សា អាត្មាអញនឹងស្ងៀមនៅពុំបាន ចាំ

ភៀសប្រាណ ចុះទៅកាន់សំណាក់ព្រះអង្គ សូមឱ្យទ្រង់ព្រះរាជទានព្រះមទ្រី ឱ្យបានគ្រាន់តែជាហេតុបន្តិចហើយ សន្សឹមអញថ្វាយសម្តេចព្រះពុទ្ធវង្សវិញ ទើបក្សត្រទាំងពីរព្រះអង្គ នឹងបានគង់នៅក្សេមក្សាន្ត សម្រាន្តព្រះរាជហឫទ័យ នៅឰដ៏ព្រះអាស្រមបទនោះឯងហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសាន្ទូវបាទព្រះគាថាដូច្នេះ ៖

តតោ រត្យា វិវសនេ     សុរិយស្សុគ្គមនំ បតិ<br>
សក្កោ ព្រាហ្មណវណ្ណេន     ចាតោ នេសំ អទិស្សថាតិ

ភិក្ខវេ ម្នាលសង្ឃដ៏ទ្រង់សីល សមាធិ បញ្ញា តតោ រត្យា នាកាលអរុណោទ័យ រស្មីភ្លឺស្រឡះបំព្រាងស្រាងស្រេច សម្តេចព្រះសហស្សនេត្រ ប្លែងភេទដោយមហិទ្ធិឫទ្ធិ និម្មិតឱ្យដូចជាព្រាហ្មណ៍ស្គាយយាមកាន់ឈើច្រត់រំពាត់ឫស្សី សម្បុរលឿងទុំ បន្សំនូវអស់គ្រឿងបរិក្ខារ ធ្វើអាការកិរិយាពុំឱ្យក្សត្រទាំងពីរព្រះអង្គសង្ស័យ

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះទ័យឡើយ ដើរទន្ទបលលបចូលដល់ហើយ អង្គុយនាមុខព្រះអាស្រម លើកហត្ថាប្រណម្យនមស្ការ ក្រាបទូលសួរដោយបាទគាថាដូច្នេះ ៖

កច្ចិ នុ ភោតោ កុសលំ    កច្ចិ ភោតោ អនាមយំ
កច្ចិ ឧញ្ឆេន យាបេថ    កច្ចិ មូលផលា ពហូ ។
កច្ចិ ឌំសា ច មកសា ច    អប្បមេវ សិរីសបា
វនេ វាឡមិគាកិណ្ណេ    កច្ចិ ហឹសា ន វិជ្ជតីតិ ។

ភោ តាបស បពិត្រព្រះតាបសដ៏មានព្រះទ័យសប្បុរសអើយ កច្ចិ នុ ខ្ញុំតាជីសុំសួរអំពីទុក្ខសោករោគា ដែលឃាយីព្រះកាយ ឬមួយពុំមានសេចក្តីក្តៅក្រហាយរំជួលក្នុងព្រះអង្គ ឬមួយស្តេចគង់ច្រើនមេត្តាភាវនា អស់ពាឡម្រឹគា តើញ៉ាំងមានមករំលោយរំលោងព្រះអាស្រម ឬមួយទ្រង់ចំរើនព្រហ្មវិហារសាមគ្គីញាណ អស់សត្វផងពុំហ៊ានមកពាធាទេ មូលផលា ពហូ មួយសោត ផលាហារនៅនាឋាននេះ តើញ៉ាំងមានបរិបូណ៌ពុំក្រ គ្រាន់រកឆាន់បាន ឬពុំសូវមានទេព្រះអង្គ ទាំងមមាចមមង់ មូស សុច ស្រាំងស្រួយ ពស់ ក្អែប

Websites: WatKhemaraRatanaram.org or WatKhmers.org

ខ្ទួយ មោះ មកឆីឈាមជាអាហារ ឬមួយបណ្ដាលពុំឱ្យកើតមាន ស្ដេចគង់នៅក្បែរមកក្សាន្តទេណាអម្ចាស់ ។ បពិត្រពុំគួរណាស់ តាមតែទ្រង់ព្រះករុណាអត់ទោស សន្ដោសប្រោសប្រាណប្រណី ខ្ញុំតាជីចាស់ជរានាកាលគ្រានេះឯងហោង ។

ឯវំ វុត្តេបិ មហាសត្តោ កាលឥន្ទ្រព្រាហ្មណ៍ ក្រាបបង្គំទូលយ៉ាងនេះហើយ ទើបព្រះពុទ្ធវង្ស ទ្រង់សំណេះសំណាលរាក់ទាក់តបទៅតាជីព្រាហ្មណ៍ មានព្រះបន្ទូលសូត្រជាបាទព្រះគាថាដូច្នេះ ៖

កុសលញ្ចេវ នោ ព្រហ្មេ អថោ ព្រហ្មេ អនាមយំ
អថោ ឧញ្ឆេន យាបេម អថោ មូលផលា ពហូ ។
អថោ ឌំសា ច មកសា អប្បមេវ សិរីសបា
វនេ វាឡមិគាកិណ្ណ ហឹសា មយ្ហំ ន វិជ្ជតិ ។
សត្ត នោ មាសេ វសតំ អរញ្ញេ ជីវិសោកិនំ
ឥទំបិ ទុតិយំ បស្សាម ព្រាហ្មណំ ទេវវណ្ណិនំ
អនាយ វសុំ ឧណ្ហំ ជាវេន្តំ អជិនក្ខិបំ ។
ស្វាគតន្តេ មហាព្រហ្មេ អថោ តេ អទុរាគតំ

Websites: WatKhemaraRatanaram.org or WatKhmers.org

អន្តោ បវិស កន្ទន្តេ ចាទេ បក្ខាលយស្សុ តេ ។
តិណ្ឌុកានិ បិយាលានិ មធុកេ កាសមារិយោ
ផលានិ ខុទ្ទកប្បានិ ភុញ្ជ ព្រហ្មេ វរំ វរំ ។
ឥទំបិ បានិយំ សីតំ អាភតំ គិរិគព្ភរា
តតោ បិវ មហាព្រហ្មេ សចេ ត្វំ អភិកង្ខសីតិ ។

ព្រាហ្មណ៍អើយ វិទុក្ខសោករោគាម្រឹគពាឡយង់ឃ្នង ក៏ពុំមានមកប៉ងបៀតបៀនពាធាយាយី នៅសព្វថ្ងៃប្រក្រតី សឹងសុខសប្បាយ ឯអស់ផលាផលផងទាំងឡាយ ដែលឆាន់ក៏ពាសពេញដោយព្រៃ គ្រាន់ប្រាស្រ័យបេះបានបរិភោគ ពុំសូវក្រណាតាជី អើពីដូចយើងចេញចាកនគរបុរី មកបួសជាតាបស សត្ត ជោ មាសេ ក៏បាន ៧ ខែប្លាយហើយ អរញ្ញេ ជីវិសោកិនំ ព្រាហ្មណ៍អើយ ពុំបានយល់មុខអ្នកឯណាមួយទៅមកដល់អាយ យល់តែសត្វផងទាំងឡាយ បានជាគ្នាកំដរក្នុងព្រៃ គ្រាន់កក់ក្តៅព្រះរាជហឫទ័យល្ហែល្ហើយ ទើបតែថ្ងៃនេះ បានយល់មុខតាជីអាចារ្យ ប្រកបប្រការនូវស្រីស្ងួស្តីឧត្តម សមខាងសៃយភេទ ឥទំបិ ទុតិយំ ពុំឃ្លាតលង្វែកយូរ

ជាគម្រប់ពីរដងបរិបូណ៌  តាំងអំពីម្សិលមិញនោះ  ក្នុងចិត្តស្មោះសរ ត្រេកអរឥតឧបមា អើព្រាហ្មណ៍អើយ សង្ខាតយាត្រាមកដល់អាស្រម កុំបីបារម្ភក្រែងចិត្តយើងឡើយណាព្រាហ្មណ៍តាមតែចិត្តនឹកចុះ បក្ខា-លយស្ស អញ្ជើញងូតទឹកជំរះញើសក្អែលឱ្យក្សេមក្សាន្តត្រអាល កុញ្ជព្រហ្មេ អស់ផលាហារ ដែលឆាន់សល់អំពីម្សិលមិញ ក៏មានគ្រប់ពណ៌ ទាំងឡាយ ខ្នុរ ស្វាយ ព្រីង ព្រូស ជន្លូស ព្និលព្នៅ ត្រាវ ដំឡូង ដូង ដងអង្គាល់  មង្ឃុត ល្មុត សេដា ម័កប្រេង ម័កប្រាង លាំងសាត សិរមាន់ សឹងដ៏មានរសពិសា ពុំជូចត់ល្វីងឡើយ ទាំងទឹកឃ្មុំផ្អែម ៗ ដ៏ជាចំណីព្រៃ តាមតែរើសឆាន់ ក៏មាននៅនាឋាននេះឯងហោង ។

ឯវំ តេន សទ្ធឹ បដិសណ្ឋារំ កត្វា មហាសត្តោ  អាហ ព្រះបរមពោធិសត្វសំណេះសំណាល  សាកសួរឥន្ទព្រាហ្មណ៍  ជាការគួរសមតាមទំនៀម ទើបមានព្រះបន្ទូលថា ៖

អថ ត្វំ តេន វណ្ណេន  តេន វា បន ហេតុនា
អនុប្បត្តោសិ ព្រហ្មារញ្ញំ  តំ មេ អក្ខាហិ បុច្ឆិតោតិ ។

Websites: WatKhemaraRatanaram.org  or  WatKhmers.org

អើយើងសូមសួរណាព្រាហ្មណ៍ ឯព្រៃខេត្តខេមព្រះហេម-ពាន្តនេះ កម្រអ្នកឯណានឹងដើរមកដល់ តាជីចាស់ជរាទុព៌លគ្រាំងគ្រាខ្នងកោងកំពក ឧស្សាហ៍ដើរជជ្រុលជជ្រកមកដល់អាយ ខ្វល់ខ្វាយរកថ្នាំធ្វើជាគ្រូពេទ្យ ឬមួយវង្វេងផ្លូវមកដល់ឋាននេះ ឬមួយសំណោះចង់មករកយើងនៅនាឋានអាយ ចូរតាព្រាហ្មណ៍ប្រាប់យើង នាកាលឥឡូវនេះឯងហោង ។

ឯឥន្ទព្រាហ្មណ៍ ទ្រង់បានស្តាប់ព្រះរាជឱង្ការ ស្មានស្មោះពីរោះសោះសា ក្រាបបង្គំទូលថា «បពិត្រព្រះមហារាជសម្ភារ ដ៏ជាឥស្សូរ រីខ្ញុំតាជីនេះ ជាមនុស្សចាស់ជរាខំត្រាច់លីលាមកដល់សំណាក់ព្រះអង្គនេះ ប្រាថ្នាតែមកសុំសម្តេចព្រះនាងមទ្រីរាជកល្យាណី ដ៏ជាព្រះអគ្គមហេសីនៃព្រះអង្គ សូមទ្រង់ប្រោសព្រះរាជទានមកខ្ញុំតាជីក្នុងកាលឥឡូវនេះ ហើយឥន្ទព្រាហ្មណ៍ក្រាបទូល សូត្រជាបាទព្រះគាថាដូច្នេះ ៖

យថា វារិវហោ បូរោ សព្វកាលំ ន ខីយតិ
ឯវន្តំ យាចិតាគច្ឆឹ ភរិយំ មេ ទេហិ យាចិតោតិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បញ្ហ មហាជនិយោ បពិត្រអម្ចាស់អើយ ខ្ញុំតាជីនឹកឧបមាព្រះរាជហឫទ័យ ប្រដូចនូវមហានទីទាំង ៥ គឺ គង្គា យមុនា អចិរវតី មហី មហានទី តែងតែមានទឹកហូរជ្រួតជ្រាបសព្វជ្រោះជ្រលងដងស្ទឹង ហើយហូរធ្លាក់ទៅក្នុងសមុទ្រ ពុំដែលផុតដាច់ខានឡើយ ។ បពិត្រអម្ចាស់អើយ សព្វសត្វមច្ឆា អណ្តើក បបែល កុម្ភីល ត្រសែ តែងមកអាស្រ័យព្រះគង្គា អស់មនុស្សម្នាប្រជាជនផង ទៅមកចុះបាចសាចងូតទឹក ដងដាក់ក្រឡពិន្ទងតាមប្រាថ្នា ព្រះគង្គានោះ ពុំដែលស្រកស្រុតរីងហួតហែងឡើយ ។ បពិត្រអម្ចាស់អើយ គួរនាបីដូចព្រះរាជហឫទ័យព្រះអង្គ លះបង់មច្ឆរិយធម៌មិបាន តែងទ្រង់ប្រោសប្រាណអស់សព្វសត្វលំបាកតោកយ៉ាកផង បើចេញពាក្យសុំអ្វីក៏សឹងបានដូចចិត្ត ទាំងនេះខ្ញុំតាជីពោលពាក្យពិតពុំមុសា ។ មួយសោត ខ្ញុំតាជីក៏ចាស់ជរាណាស់ហើយ ពុំដូចកាលពីមុនឡើយដែលខ្លួននៅកម្លោះឥឡូវមានរោគាមកបៀតបៀនក្នុងអង្គ ទាំងត្រចៀកក៏ថ្លង់ភ្នែកងងឹតទាំងញាតិសាច់ទៀបជិតក៏ស្លាប់បាត់បង់អស់ហើយ ព្រះគុណអើយ សព្វថ្ងៃនេះ នៅកំព្រាទីទ័ល ទោះបីផ្លូវកម្រឆ្ងាយប៉ុន្មានក្តីក៏មិនថា

Websites: WatKhemaraRatanaram.org or WatKhmers.org

ឧស្សាហ៍ជជ្រុលជជ្រកឱ្យបានមកដល់អម្ចាស់ ពុំគួរណាស់តាមតែទ្រង់ព្រះមេត្តាប្រោសអត់ទោសត្រាប្រណីខ្ញុំតាជី សូមព្រះរាជទានសម្ដេចព្រះរាជមទ្រីទៅធ្វើជាមេផ្ទះគ្រាន់បានជាគ្នាកំដរ ខ្ញុំតាជីចាស់ជរាសោះស្វាត់ សូមព្រះអង្គកាត់ឱ្យជាទានឃឹតយកសព្វេជ្ញុតាញ្ញាណ យកព្រះមទ្រីបរិច្ចាគឱ្យជាទានខ្ញុំតាជី នាកាលគ្រាឥឡូវនេះឯងហោង ។

ឯវំ វុត្តេបិ មហាសត្តោ សម្ដេចព្រះបរមពោធិសត្វបានស្ដាប់ឥន្ទព្រាហ្មណ៍ ក្រាបទូលថ្លែងសេចក្ដីលំបាកទាំងនោះ តាំងចិត្តស្មោះចំពោះមកសូមព្រះរាជទានព្រះអគ្គជាយានាថ្ងៃនោះ ព្រះអង្គក៏ស្មោះសរក្នុងព្រះរាជហឫទ័យ មិនមានសង្ស័យរួញរា ត្បិតអំពីថ្ងៃម្សិលមិញ ទ្រង់ព្រះរាជទានបុត្រាបុត្រីទៅជូជកព្រាហ្មណ៍ ដល់មកថ្ងៃនេះ យើងនៅក្នុងព្រៃតែម្នាក់ឯង នឹងលើកសម្ដេចព្រះនាងមទ្រីឱ្យទៅជាទានព្រះស្ដែងដូចម្ដេចបាន ព្រះអង្គនឹងមានព្រះរាជហឫទ័យថុចថយរួញរាដូច្នេះ ឥតអង្គីមានឡើយ ហេតុតែព្រះអង្គស្រឡាញ់សព្វេជ្ញុតាញ្ញាណ ឧបមាបីដូចអ្នកខ្សត់ទ្រព្យ មានបុគ្គលអ្នករាប់យកមាសប្រាក់មកចាក់គរឱ្យដល់ដៃ ព្រះភក្ត្រញញឹមប្រិមប្រិយ មានព្រះ

Websites: WatKhemaraRatanaram.org or WatKhmers.org

បន្ទូលថ្លែងនូវព្រះគាថានេះថា ៖

ទទាមិ ន វិកម្បាមិ យំ មំ យាចសិ ព្រាហ្មណ
សន្តំ នប្បដិគូហាមិ ទានេ មេ មេតេ មនោតិ ។

ម្នាលព្រះស្តេងព្រាហ្មណ៍អើយ យើងនឹងលើកសម្តេចព្រះភគវតី នាងមទ្រីឱ្យជាទានតាជីតាមសេចក្តីសុំ យើងមិនមានចិត្តរំភើបរួញរានឹងការបរិច្ចាគទាន ព្រោះចិត្តយើងត្រេកអរនឹងទាន ពុំដែលមានលាក់បំបាំងរបស់អ្វីនឹងស្មូមយាចកឡើយ អើតាជី កុំថាឡើយតែនាងមទ្រីជាពាហិរទាន បើមានស្មូមមកប៉ងប្រាថ្នាសាច់ ស្បួត ថ្លើម ដង្ហើមប្រមាត់ ក៏នឹងកាត់ឱ្យជាទានតាមសុចរិតយកជីវិតឱ្យជាទាន ដូរយកសព្វេជ្ញូតាញាណសាស្តាចារ្យ ប្រាថ្នាតែបានត្រាស់ជាព្រះពុទ្ធ នាំអស់សព្វសត្វឆ្លងវដ្តសង្សារ ទៅកាន់ត្រើយព្រះអមតមហានិព្វាននាយនោះហោង ។

លុះព្រះមហាសត្វ មានព្រះបន្ទូលយ៉ាងនេះហើយស្រេចស្តេចយកព្រះកុណ្ឌីដងព្រះឧទកៈច្រួចលើដៃព្រាហ្មណ៍ភ្លាម ទ្រង់ព្ររាជទានព្រះអគ្គជាយាទៅឥន្ទព្រាហ្មណ៍ ឰដ៏កាលនោះឯងហោង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ហេតុអស្ចារ្យផ្សេង ៗ ក៏កើតមានប្រាកដ ព្រមល្មមគ្នាក្នុងខណៈនោះ ដូចកាលព្រះអង្គទ្រង់ព្រះរាជទានព្រះរាជបុត្រាបុត្រី ទៅជូជកព្រាហ្មណ៍ព្រឹទ្ធាចារ្យ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសាន្ទវបាទព្រះគាថាដូច្នេះ ៖

មទ្ទឹ ហត្ថេ គហេត្វាន ឧទកស្ស កមណ្ឌលុំ
ព្រាហ្មណស្ស អទា ទានំ សិវីនំ រដ្ឋវឌ្ឍនោ ។
តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ
មទ្ទឹំ បរិច្ចជន្តស្ស មេទនី សមកម្បថ ។
នេវស្ស មទ្ទី ភកុដី ន សន្ធីយតិ ន រោទតិ
បេក្ខតេវស្ស តុណ្ហីយា ឯស ជានាតិ យំ វរន្តិ ។

កាលនោះ សម្តេចព្រះមហាសត្វ ទ្រង់កាន់ព្រះករបវររាជមទ្រី រួចទ្រង់ចាប់យកព្រះកណ្ឌី ច្រូចព្រះឧទកវារីហៀរហូរ ជាសញ្ញាថា ទ្រង់ព្រះរាជទានសម្តេចព្រះមទ្រីទៅព្រាហ្មណ៍ជ្រះស្រឡះ

Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយ ដោយទ្រង់មានព្រះរាជហឫទ័យ ប្រកបដោយត្រៃហេតុបរមត្ថ ជាមហាម្កុដនៃទាន ទើបមានព្រះរាជឱង្ការថា «អើតាជី មទ្រីនេះជាសំឡាញ់ជាប្រធាន មានពិព្យាយាម តាមមកប្រណិប័តន៍ តាំងសាងព្រតនៅក្នុងព្រៃ ទុកស្មើព្រះនេត្រនៃយើងមិញ យើងមិនស្រឡាញ់ស្មើនឹងព្រះសព្វញ្ញុតញ្ញាណបាន ១ សែនកម្លាំងទេ ឥចំ ជាធំ រីទានទាំងនេះ សូមជាបច្ច័យបានត្រាស់នូវព្រះបរមាភិសម្ពោធិញ្ញាណ ជាឯកអគ្គបុគ្គល នាំសត្វឆ្លងចាកវដ្តសង្សារ ឱ្យបានដល់ត្រើយគឺព្រះនិព្វាន ទៅអនាគតកាលនោះឯងហោង ។

វុត្តម្បិ ចេតំ ពាក្យនេះ សមដូចបាលីគាថាដែលលោកសម្តែងទុកក្នុងគម្ពីរចរិយាបិដកដូច្នេះ ៖

ជាលឹ កណ្ហាជិនំ ធីតំ មទ្ទឹ ទេវឹ បតិព្វតំ
ចជ្ជមានោ ន ចិន្តេសឹ ពោធិយាយេវ ការណា ។
ន មេ ទេស្សា ឧភោ បុត្តា មទ្ទី ទេវី ន អប្បិយា
សព្វញ្ញុតំ បិយំ មយ្ហំ តស្មា បិយេ អទាសហន្តិ ។

កាលតថាគត នៅជាព្រះវេស្សន្តរ បានបរិច្ចាគលះបង់ជាលី

Websites: WatKhemaraRatanaram.org or WatKhmers.org

ក្រស្នា និងសម្ដេចព្រះរាជមទ្រីទេវី ដ៏មានវត្តប្រណិប័តន៍ដ៏ប្រពៃ ឱ្យជាទានព្រាហ្មណ៍ តថាគតមិនមានចិត្តគិតសោកស្ដាយសោះឡើយ ព្រោះតថាគត ប្រាថ្នាតែឱ្យបានសម្រេចព្រះពោធិញ្ញាណប៉ុណ្ណោះ ។ មួយវិញទៀត ព្រះរាជបុត្រទាំងពីរ តថាគតមិនស្អប់ខ្ពើមទេ ទាំងសម្ដេចព្រះមទ្រីទេវីសោត ក៏មិនមែនតថាគតមិនស្រឡាញ់ដែរ ប៉ុន្តែតថាគតស្រឡាញ់សព្វញ្ញុតញ្ញាណក្រៃលែង ហេតុហ្នឹងហើយបានជាតថាគត បានឱ្យរបស់សម្លាញ់ទៅជាទាន ដូរយកព្រះសព្វញ្ញុតញ្ញាណក្នុងកាលនោះឯងហោង ។

នាកាលព្រះបរមពោធិសត្វ ទ្រង់ព្រះរាជទានអគ្គជាយាទៅឥន្ទព្រាហ្មណ៍ ក៏កើតមានអស្ចារ្យកក្រើកញាប់ញ័រ សព្វសកលលោកធាតុតាំងអំពីអជដាកាស ក៏កើតកោលាហល រីខ្យល់ទឹកបក់បោកទៅមកសព្វទិសទី រីទឹករងព្រះធរណី ក៏ក្ដៅពុះពោរជោរជន់ជាចលាចល ដីកម្រាស់ ២ សេន ៤ ម៉ឺនយោជន៍ក៏ពុំអាចទប់បាន ដូចនឹងរលាយរលំលាន់គគ្រេងគគ្រាំពសុធា មត្តវាណោ វិយ បីដូចគជសារចុះប្រេងឧទារជ្រួតជ្រាបដាបមាត់រត់រពាទ៍ ស្រែកសំទារពុំក្រែងខ្លាច

Websites: WatKhemaraRatanaram.org or WatKhmers.org

ដូច្នោះ សារពើសត្វ គោព្រៃ ប្រើស ខ្លា ទ្រាយ ទន្សាយ សិង្ហសីហ៍ បណ្ដាសព្វសត្វនៅដី សឹងភិតភ័យរលះរលាំង ស្ទុះផ្លោះចេញពីលំនៅ រត់ទៅជជ្រុលជជ្រកសព្វព្រៃ រីគជសីហ៍ក៏ស្រែកសំទារអឺអឹង ភឹសឆគាំ ខ្ទរខ្ទារទ្រហឹងជាពន្លឹក មុខគួរឱ្យភិតភ័យ សូរសព្ទអាកាសចុះអ័ព្ទងងឹត ទាំងវេហាស៍ លោមហំសជំ កើតជារងាព្រឺស្រៀវស្រាញស្លប់ស្លែង អកាលវិជ្ជុតា ពុំជារដូវភ្លៀង ក៏កើតមានផ្លេកបន្ទោរដាលដាស នាអាកាសវិថីអសនីរស្មីពព្លមលលាមផ្ទៃលឆ្វាត់ ដូចរត្នមណីជុំប្រិថពី មណ្ឌលចក្រវាឡ ក៏កើតជាខ្យល់ព្យុះបោកបក់ ព្ទសព្ទគគ្រឹកគគឹកទាំងវេហាស៍ អស់ព្រៃព្រឹក្សាក៏បាក់ផ្ងងផាងរលំ សាគរ ទាំងសមុទ្រសាគរដ៏ធំធេង ក៏លាន់សំឡេងចឆចឆា គគ្រឹកគគ្រេងបោកបែកជាផ្កាត្រែងត្រាពាសពេញជាពពុះទាំងព្រះគង្គា អស់ហ្វូងតិមិតិមង្គលាមធ្វាផងក៏ហែលឆ្វៀលឆ្វាត់វេរា ហ្វូងមករហែលជារង់ អស់ស្ដេចនាគភុជង្គ អនេកនានា នាងនាគីនិម្មិតជាមាលា បន្សាត់មកថ្វាយក្បែមក្បាន្ត សប្បាយតាមជលធី សិនេរុបព្វតរាជា ទាំងភ្នំសិនេរុរាជគិរី ពុំអាចនឹងនៅ ក៏ទោរទន់ទៅមក ហាក់ដូចនឹងរលំដូចអភិវាទន៍ ក្រាបថ្វាយបង្គំ

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះបរមពោធិសត្វ វេត្តង្ករោ វិយ បីដូចអ្នកកាន់ចុងដំបងទងផ្តៅពោល ភ្លើង ហើយលើកឡើងបញ្ឈរ សឹងដ៏ទន់ទោរទាំងឆកាមាវចរសួគ៌ទេវគណា ទាំងសោឡសសួគ៌ា ក៏ក្បែមក្សាន្តបូជាបុប្ផា ខ្លះប្រោយរាយសុគន្ធមាលាបារិជាត នាកណ្តាលនភាកាស ក៏ប្រគំសំឡេងត្រែស័ង្ខភេរី តូរ្យតន្ត្រីល្វើយល្វេង ខ្លះច្រៀងសរសើរព្រះសម្ភារថ្វាយសព្វសាធុការព្រះអង្គ ។ បពិត្រអម្ចាស់អើយ សូមព្រះអង្គមានព្រះជន្មដ៏លង់ ១ ពាន់ព្រះវស្សា ពុំមានអ្នកឯណាស្មើនឹងព្រះអង្គបានត្បិតព្រះអង្គជាពង្សពុទ្ធង្កូរគួរបូជា ឯកកោលាហលំ រីឯព្យោមាគឺព្យុះភ្លៀងខ្យល់កក្រើកសព្វសកលលោកធាតុ តាំងអំពីអជដាកាសទៅដល់សុទ្ធាវាសមហាព្រហ្ម ក្បែមក្សាន្តអភិរមស្មើឯកអង្គា នាកាលព្រះអង្គលើកយកព្រះអគ្គជាយាឱ្យជាឧត្តមបរមទានដល់ឥន្ទព្រាហ្មណ៍ព្រឹទ្ធាចារ្យក្នុងកាលនោះឯងហោង ។

ភិក្ខវេ ម្នាលសង្ឃ ដ៏ទ្រង់សីលសំវរៈ នាកាលសម្តេចព្រះវេស្សន្តរបវរពុទ្ធង្កូរ ព្រះអង្គព្រះរាជទានព្រះមទ្រី ឱ្យទៅតាជីចាស់ជរា ទ្រង់ព្រះចិន្តាគិតបារម្ភ ត្បិតពុំសមសេចក្តី ក្រែងពុំត្រូវព្រះរាជ

Websites: WatKhemaraRatanaram.org or WatKhmers.org

ហឫទ័យនៃព្រះអគ្គជាយា នឹងរួញរាថុចថយសទ្ធា បណ្តាលឱ្យកើតជាទុក្ខសោកា តាមធម្មតាប្រពៃណីលោកិយ បើក្រមុំកម្លោះនោះ ទើបសមនឹងគ្នា ឥឡូវនេះនាងបានទៅព្រាហ្មណ៍ចាស់ជរាព្រឹទ្ធាចារ្យ ជាមនុស្សអន្ធការ ហិនទ្រព្យអប្បយសសក្តិ យល់ជានាងនឹងធ្លាក់ថ្លោះ ពុំពេញព្រះរាជហឫទ័យ ធម្មតាវិស័យចិត្តលោកិយផងទាំងឡាយ ពុំដែលជៀសឆ្ងាយពីគ្នា ទើបសម្តេចព្រះបរមរាជា ស្តេចផ្ទៀងព្រះនេត្រមើលព្រះអគ្គមហេសី ឱ្យបានជ្រាបអាការកិរិយា ។ ឯព្រះនាងក៏បានដឹងក្នុងព្រះប្រាជ្ញាអធ្យាស្រ័យ ដឹងក្នុងព្រះរាជហឫទ័យព្រះស្វាមី ទើបព្រះនាងលើកអញ្ជលីអភិវាទ ក្រាបបង្គំទូលថា

កោមារី យស្សាហំ ភរិយា សាមិកោ មម ឥស្សរោ

យស្សិច្ឆេ តស្ស មំ ទជ្ជា វិក្កិណេយ្យ ហនេយ្យ វាតិ ។

បពិត្រអម្ចាស់អើយ កុំថាតែព្រះអង្គឱ្យទានខ្ញុំទៅព្រាហ្មណ៍ចាស់ជរាក្រែងអាក់អន់ចិត្ត ព្រះគុណអើយ បើព្រាហ្មណ៍គាត់ប្រាថ្នាសាច់ ឈាមថ្លើម ដង្ហើមប្រមាត់ ក៏សូមស្តេចយកព្រះខ័នកាត់ខ្ញុំមទ្រីនេះចេញបំពេញព្រះបារមីទាន ឬមួយក្រែងព្រាហ្មណ៍មានបើប្រាថ្នា

Websites: WatKhemaraRatanaram.org or WatKhmers.org

នឹងចង់យកជាទ្រព្យ គឺមាសប្រាក់ កែវកង សព្វពិធរត្នផងទាំងឡាយ ក៏សូមស្តេចនាំមទ្រីទៅចំណាយ យកជាទ្រព្យមកគរ បំពេញព្រះរាជសទ្ធា ឱ្យទៅជាទានព្រាហ្មណ៍ ខ្ញុំមទ្រីពុំមានចិត្តរួញរានឹងសុំយកអាសាស្នងព្រះតេជគុណ ដរាបលុះអស់ជីវិត ។ សូមជួយបំពេញព្រះបារមីទាន សូមឱ្យព្រះអង្គបានត្រាស់ជាព្រះពុទ្ធ នាំសត្វចូលព្រះនិព្វាន បានដូចសេចក្តីប្រាថ្នាអានាគតកាលទៅហោង ។

កាលនោះសម្តេចព្រះឥន្ទ្រាធិរាជ ទ្រង់ជ្រាបសភាពព្រះរាជអធ្យាស្រ័យដ៏ប្រសើរថ្លៃថ្លា នៃក្សត្រាក្សត្រីទាំងពីរព្រះអង្គនោះហើយ ក៏ទ្រង់ត្រាស់សរសើរព្រះបរមពោធិសត្វជាយ៉ាងក្រៃលេង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រជាបាទព្រះគាថាដូច្នេះ ៖

តេសំ សង្កប្បមញ្ញាយ ទេវិន្ទោ ឯតទព្រវិ
សព្វេ ជិតា តេ បច្ចូហា យេ ទិព្វា យេ ច មានុសា ។
និន្នាទិតា តេ បថវី សទ្ទោ តេ តិទិវង្គតោ

Websites: WatKhemaraRatanaram.org or WatKhmers.org

សមន្តា វិជ្ជុតា អាគូ   តិរីដំវ បជិស្សុតា ។
តស្ស តេ អនុមោទន្តិ   ឧភោ ជារធបព្វតា
ឥន្ទោ ច ព្រហ្មា ច បជាបតី ច
សោមោ យមោ វេស្សវណោ ច រាជា
សព្វេ ទេវានុមោទន្តិ   ទុក្ករំ ហិ ករោតិ សោ ។
ទុទ្ទទំ ទទមានានំ   ទុក្ករំ កម្មកុព្វតំ
អសន្តោ នានុកុព្វន្តិ   សតំ ធម្មោ ទុរន្វយោ ។
តស្មា សតញ្ច អសតញ្ច   នានា ហោតិ ឥតោ គតិ
អសន្តោ និរយំ យន្តិ   សន្តោ សគ្គបរាយនា ។
យមេតំ កុមារេ អទា   ភរិយំ អទា វនេ វសំ
ព្រហ្មយានមនោក្កម្ម   សគ្គេ តេ តំ វិបច្ចតូតិ ។

ភិក្ខវេ ម្នាលសង្ឃដ៏ទ្រង់សីលសិក្ខា សម្តេចព្រះអមរិន្ទ្រាធិរាជ ទ្រង់ជ្រាបសេចក្តីអំពីក្សត្រាក្សត្រីទាំងពីរព្រះអង្គ តាំងព្រះទ័យព្រះរាជសទ្ធា ព្រះឥន្ទ្រាធិរាជក៏ត្រេកអរក្សេមក្សាន្ត ទើបក្រាបទូល

សរសើរថា «បពិត្រព្រះរាជសម្ភារ តេ បច្ចុហា រីអន្ទាក់នៃមារដែលមករាំងរាមិនឱ្យបានសម្រេចសម្បត្តិមនុស្សលោក សម្បត្តិសួគ៌ និងសម្បត្តិព្រះនិព្វាន ក៏ព្រះអង្គមានជ័យជំនះ ឈ្នះទាំងអស់ឥតមានសេសសល់ ទាល់តែកើតចលាចល អស្វារ្យទាំងផ្ទៃផែនដី មានព្រះកិត្តិស័ព្ទល្បីរហូតទៅដល់ត្រៃទិព្វសួគ៌នាយ ទាំងផ្លេកបន្ទោរ ក៏ដាលច្រវាត់ជុំវិញព្រៃព្រះហេមពាន្ត ទាំងភ្នំនារទបព៌ត ក៏ហាក់ដូចជាមានចិត្តត្រេកអរអនុមោទនាបារមីនៃព្រះអង្គ ។ ព្រះឥន្ទ ព្រះព្រហ្ម ព្រះយមរាជ ព្រះបជាបតី ព្រះចន្ទ្រ ព្រះបាទវេស្សវ័ណ ព្រមទាំងទេវតាទាំងឡាយ នាំគ្នាថ្វាយសព្វសាធុការអនុមោទនាទានបារមីនៃព្រះអង្គ ព្រោះទ្រង់ធ្វើអំពើដែលបុគ្គលដទៃធ្វើតាមស្នាមព្រះបាទពុំទាន់ឡើយ ។ ព្រះអង្គអាចព្រះរាជទានរបស់ដែលគេឱ្យបានដោយកម្រ ទ្រង់ធ្វើអំពើដែលគេធ្វើបានដោយកម្រ ទើបអសប្បុរសធ្វើតាមព្រះអង្គពុំបានឡើយ មានតែពួកសប្បុរសទើបត្រាច់ទៅតាមលំអានស្នាមព្រះបាទបាន ។ ហេតុនេះបានជាដំណើររបស់ពួកសប្បុរស និងរបស់ពួកអសប្បុរស រមែងប្លែកផ្សេងគ្នា គឺពួកអសប្បុរសតែងនាំគ្នាទៅនរក ឯពួកសប្បុរសតែងនាំគ្នា

Websites: WatKhemaraRatanaram.org or WatKhmers.org

ទៅឋានសួគ៌ ។ បពិត្រព្រះវេស្សន្តរក្សត្រប្រសើរអើយ ការដែលស្ដេចត្រាច់មកគង់ក្នុងព្រៃព្រឹក្សាយ៉ាងនេះហើយ នៅតែទ្រង់ព្រះរាជសទ្ធាទ្រង់បរិច្ចាគព្រះរាជបុត្រាបុត្រី និងព្រះអគ្គមហេសីជាទាន ពុំមានព្រះរាជហឫទ័យរួញរា ទុកជាព្រហ្មយានដ៏ប្រសើរវិសេស សូមឱ្យបុត្តទារមហាទាននេះ ចូរសម្រេចផលដល់សួគ៌នាយទៅមុខហោង» ។

លុះព្រះឥន្ទ្រាធិរាជ អនុមោទនាសរសើរ នូវទានបារមីនៃព្រះមហាសត្វ ដោយប្រការដូច្នេះហើយ ទើបទ្រង់ព្រះតំរិះថា «គួរតែអាត្មាអញ ប្រគល់សម្ដេចព្រះនាងមទ្រី ទៅព្រះអង្គវិញក្នុងវេលាគ្រាឥឡូវនេះឯង» ។ ព្រះបាទកោសិយទេវរាជ ក៏មានព្រះរាជឱង្ការសូត្រសានូវបាទព្រះគាថាដូច្នេះ ៖

ឧជាមិ ភោតោ ភរិយំ មទ្ទិំ សព្វង្គសោភិនឹ
ត្វញ្ចេវ មទ្ទិយា ឆន្នោ មទ្ទី ច បតិនា សហ ។
យថា បយោ ច សង្ខោ ច ឧភោ សមានវណ្ណិនោ
ឯវំ តុវញ្ច មទ្ទី ច សមានមនចេតសា ។
អវរុទ្ធេត្ថ អរញ្ញស្មឹ ឧភោ សម្មថ អស្សមេ

Websites: WatKhemaraRatanaram.org or WatKhmers.org

ខត្តិយា គោត្តសម្បន្នា សុជាតា មាតុបេតិតោ
យថា បុញ្ញានិ កាយិរាថ ឥនន្តា អបរាបរន្តិ ។

បពិត្រក្សត្រថ្លៃប្រសើរអើយ រីសម្ដេចព្រះរាជមទ្រីនេះ ទុកស្មើព្រះនេត្ររបស់ព្រះអង្គ ពុំនោះសោតដូចកលជីវិត ព្រះអង្គពុំគិតឧស្សាហ៍លះបង់ឱ្យជាទាន កម្របុគ្គលឯណាមួយនឹងធ្វើបានដូចព្រះអង្គ សូមព្រះអង្គទ្រង់ព្រះមេត្តាអត់ទោសប្រោសខ្ញុំតាជី ត្បិតស្ដេចលើកយកព្រះរាជមទ្រីឱ្យទៅជាទាន ព្រះគុណនោះធំធ្ងន់ពន់ប្រមាណ ខ្ញុំតាជីទទួលព្រះរាជទានទុកលើសិរសា ត្បិតខ្ញុំតាជីក៏ចាស់ជរា រោគាក៏បៀតបៀនក្នុងខ្លួនប្រាណ ហើយជិតចូននឹងមរណា រូបក៏អន្ទការតតខ្លឹមសារសូន្យសោះ នឹងទទួលព្រះរាជទាននោះ យល់ពុំគាប់ជាទ្រព្យសទ្ធា ។ មួយសោត ព្រះអង្គជាអំបូរត្រកូលខត្តិយវង្ស រែងទ្រង់ព្រះរាជសទ្ធាត្រកាលលើសលែងមនុស្សសត្វផងទាំងឡាយ បើនឹងអភិប្រាយបីដូចស័ង្ខដ៏បរិសុទ្ធ ពុំនោះសោត បីដូចទឹកដោះដ៏មានរស្មី យល់ព្រះបារមីជាត្រកាល ខ្ញុំតាជីក៏ត្រេកអរសោមនស្ស នឹងព្រះរាជហឫទ័យសូមថ្វាយព្រះរាជមទ្រីដល់ព្រះអង្គវិញ នឹងបានបំពេញមេត្តាព្រហ្ម-

Websites: WatKhemaraRatanaram.org or WatKhmers.org

វិហារពុំឱ្យមានអំពល់ ដើម្បីចំរើនព្រះរាជកុសល ឱ្យបានចំរើនកើនទៅមុខទៀត នឹងបាននាំសត្វទៅទុកឯអម្រឹតបុរីស្រីមហានគរនិព្វានហោង ។

សម្តេចព្រះឥន្ទ្រាធិរាជក្រាបទូលស្រេចហើយ ពុំលង់ឡើយទើបសម្តែងព្រះអង្គ ឱ្យព្រះបរមពោធិសត្វជ្រាបច្បាស់ថា ព្រះអង្គគឺអង្គអមរេន្ទ្រាធិរាជ ហើយទ្រង់មានទេវឱង្ការព្រះរាជទានព្រះពរដូច្នេះ ៖

សក្កោហមស្មិ ទេវិន្ទោ អាគតោស្មិ តវន្តិកេ
វរំ វរស្សុ រាជិសិ វរេ អដ្ឋ ទទាមិ តេតិ ។

បពិត្រព្រះអង្គដ៏ទ្រង់នូវព្រះរាជសទ្ធាអើយ រីខ្លួនអញខ្ញុំនេះពុំគឺព្រាហ្មណ៍ព្រឹទ្ធាចារ្យឡើយ អញខ្ញុំនេះ គឺជាកោសិយអមរេន្ទ្រាធិរាជ ឋិតនៅនាឋានត្រៃត្រិង្សា ចុះមកទំនុកបំរុងបំពេញទានបារមីដើម្បីឱ្យព្រះអង្គបានសម្រេចព្រះសម្ពោធិសម្ភារ ហើយនឹងថ្វាយព្រះពរ ៨ ប្រការដល់ព្រះអង្គ នាកាលគ្រាឥឡូវនេះឯង ។

កាលសម្តេចព្រះអមរេន្ទ្រាធិរាជកំពុងមានព្រះរាជឱង្ការនេះ ទ្រង់តំណែងប្លែងអត្តភាពជាទិព្វមួយរំពេច មានពន្លឺរស្មីព្រោងព្រាយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ពណ្ណរាយឆើតឆាយ ទ្រង់ធ្យានឡើងទៅបិតព្វដ៏នភាកាស មានពន្លឺរស្មីរុងរឿង ដូចកាលព្រះសុរិយាទើបរះឡើងពីទិសបូព៌ា ។

តតោ ពោធិសត្តោ កាលនោះ ព្រះបរមពោធិសត្វមហាបុរសរត្ន ស្តេចទ្រង់ជ្រាបអស់អាថ៌អម្បាលណោះហើយ កាលព្រះអង្គនឹងទទួលយកព្រះពរអំពីព្រះឥន្ទ្រា ទ្រង់ក្រាបបង្គំទូលសូត្រនូវបាទព្រះគាថាទាំងឡាយដូច្នេះ ៖

វរញ្ចេ មេ អទោ សក្ក សព្វភូតានមិស្សរ
បិតា មំ អនុមោទេយ្យ ឥតោ បត្តំ សកំ ឃរំ
អាសនេន និមន្តេយ្យ បឋមេតំ វរំ វរេ ។
បុរិសស្ស វធំ ន រោចេយ្យំ អបិ កិព្វិសការកំ
វជ្ឈំ វធម្ហា មោចេយ្យំ ទុតិយេតំ វរំ វរេ ។
យេ វុឌ្ឍា យេ ច ទហរា យេ ច មជ្ឈិមបោរិសា
មមេវ ឧបជីវេយ្យុំ តតិយេតំ វរំ វរេ ។
បរទារំ ន គច្ឆេយ្យំ សទារបសុតោ សិយំ

Websites: WatKhemaraRatanaram.org or WatKhmers.org

ជីនំ រសំ ន តច្ឆេយ្យំ ចតុត្ថេតំ វរំ វរេ ។

បុត្តោ មេ សក្ក ជាយេថ សោ ច ទីឃាយុកោ សិយា

ធម្មេន ជិនេ បឋវី បញ្ចមេតំ វរំ វរេ ។

តតោ រត្យា វិវសនេ សុរិយស្សុគ្គមនំ បតិ

ទិព្យា ភក្ខា ចាតុភវេយ្យុំ ឆដ្ឋមេតំ វរំ វរេ ។

ទទតោ មេ ន ខីយេថ ទត្វា នានុតបេយ្យហំ

ទទំ ចិត្តំ បសាទេយ្យំ សត្តមេតំ វរំ វរេ ។

ឥតោ វិមុច្ចមានាហំ សគ្គគាមី វិសេសគូ

អនិវត្តី តតោ អស្សំ អដ្ឋមេតំ វរំ វរេតិ ។

បពិត្រព្រះឥន្ទ្រាធិរាជ ដ៏ជាធំចំបងអស់សព្វសត្វទាំងឡាយ ថាបើព្រះអង្គទ្រង់ព្រះរាជទានព្រះពរដល់យើងខ្ញុំមិញ ឯព្រះពរទី ១ សូមឱ្យព្រះវររាជបិតា សព្វព្រះរាជហឫទ័យត្រេកអរនឹងយើងខ្ញុំ កាលត្រឡប់ចេញពីព្រៃទៅដល់ព្រះរាជបុរីរបស់ខ្លួនហើយ សូមឱ្យព្រះវររាជបិតាអញ្ជើញយើងខ្ញុំ ឱ្យនៅគ្រប់គ្រងរាជ្យសម្បត្តិ បឋមេតំ វរំ វរេ យើង

Websites: WatKhemaraRatanaram.org or WatKhmers.org

ខ្ញុំសូមទទួលយកព្រះពរនេះជាបឋម ។

ប្រការមួយសោត កាលយើងខ្ញុំបានគ្រប់គ្រងរាជ្យសម្បត្តិហើយ សូមកុំឱ្យយើងខ្ញុំគាប់ចិត្តនឹងការសម្លាប់មនុស្សម្នា មហាជនផងទាំងឡាយ ទោះបីមានទោសខុសដល់ស្លាប់ ក៏សូមឱ្យយើងខ្ញុំជួយដោះទុក្ខសត្វឱ្យផុតពីការសម្លាប់ទាល់តែបាន ទុតិយេតំ វរំ វរេ យើងខ្ញុំសូមទទួលយកព្រះពរនេះជាគំរប់ ២ ។

ប្រការមួយសោត រីអស់មនុស្សម្នា ប្រជាជនផង ទោះចាស់ក្តី ក្រមុំកម្លោះក្តី ក្មេងក្តី ដែលមានសេចក្តីក្រីក្រកំសត់តោកយ៉ាកសូមឱ្យបានចូលមកពំនាក់អាស្រ័យយើងខ្ញុំ ទទួលព្រះរាជទានចិញ្ចឹមជីវិត ជាសប្បាយតាមប្រក្រតី តតិយេតំ វរំ វរេ យើងខ្ញុំសូមទទួលយកព្រះពរនេះជាគំរប់ ៣ ។

ប្រការមួយសោត រីមាតុគ្រាមនាំបង្កក្តីប្រមាថ ឱ្យបាត់បង់សទ្ធា ដោយក្តីតម្រេកក្នុងកាមេសុមិច្ឆាចារជាក្តីអកុសល សូមកុំឱ្យជិតដល់កើតក្នុងខន្ធសន្តាន សូមឱ្យយើងខ្ញុំបានស្នេហ៍ស្មាលនឹងព្រះរាជមទ្រី កុំបីលុះអំណាចស្ត្រីដទៃឡើយ ចតុត្ថេតំ វរំ វរេ យើងខ្ញុំសូមទទួល

Websites: WatKhemaraRatanaram.org or WatKhmers.org

យកព្រះពរនេះជាគំរប់ ៤ ។

បពិត្រសម្តេចព្រះអមរេន្ទ្រាធិរាជប្រសើរអើយ យើងខ្ញុំសូមឱ្យព្រះរាជឱរសទាំងទ្វេហារ គឺចៅជាលីនិងមេក្រស្នា មានជន្មាយុយឺនយូរ ហើយសូមឱ្យបានគ្រប់គ្រងផែនដីជេតុត្តរបុរីរដ្ឋ ដោយនូវគន្លងធម៌ នៃខត្តិយប្រពៃណី បញ្ចមេតំ វរំ វរេ យើងខ្ញុំសូមទទួលយកព្រះពរនេះជាគំរប់ ៥ ។

ប្រការមួយសោត កាលដែលយើងខ្ញុំយាត្រាទៅដល់រាជបុរីហើយ លុះអស់ងងឹតក្នុងវេលារាត្រីដល់ពេលអរុណរះឡើងថ្មី ក៏សូមឱ្យអាហារទិព្វកើតមានប្រាកដ ឱ្យបានគ្រប់គ្រាន់តាមកំណត់រាល់ ៗ ថ្ងៃ ឆដ្ឋមេតំ វរំ វរេ យើងខ្ញុំសូមទទួលយកព្រះពរនេះជាគំរប់ ៦ ។

ប្រការមួយសោត យើងខ្ញុំសូមឱ្យមានចិត្តកាត់តម្លាសទ្វាក្នុងការបរិច្ចាគទាន ទុកជាឱ្យទានអម្បាលម៉ាន កុំបីឱ្យចេះអស់សោះឡើយ កាលកំពុងឱ្យ ក៏សូមឱ្យមានចិត្តជ្រះថ្លាផូរផង់ លុះលះបង់ឱ្យហើយ ក៏កុំឱ្យមានចិត្តក្តៅក្រហាយស្តាយក្រោយឡើយ សត្តមេតំ វរំ វរេ យើងខ្ញុំសូមទទួលយកព្រះពរនេះជាគំរប់ ៧ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ប្រការមួយសោត កាលយើងខ្ញុំនឹងរំលោងខន្ធ តាមកំណត់ទិវង្គតសោយព្រះវិលាល័យ សូមឱ្យបានទៅកើតនាឋានតុសិតសួគ៌នាយ ដ៏ជាឋានវិសេស លុះច្យុតអំពីឋាននោះ ក៏សូមឱ្យបានសម្រេចព្រះបរមាភិសេកសម្ពោធិញ្ញាណ មិនមានវិលកើតវិលស្លាប់ក្នុងសង្សារភពតទៅទៀតឡើយ អដ្ឋមេតំ វរំ វរេ យើងខ្ញុំសូមទទួលយកព្រះពរនេះជាគំរប់ ៨ រួមជាព្រះពរ ៨ ប្រការ ។ ទើបសម្តេចអមរេន្ទ្រាធិរាជអាចប្រសិទ្ធិឱ្យបានដូចព្រះរាជហឫទ័យប្រាថ្នា នាអនាគតកាលនោះឯងហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសាជាបាទព្រះគាថាដូច្នេះ ៖

តស្ស តំ វចនំ សុត្វា ទេវិន្ទោ ឯតទព្រវិ
អចិរំ វត តេ តាតោ បិតា តំ ទដ្ឋុមេស្សតិ ។
ឥទំ វត្វាន មឃវា ទេវរាជា សុជម្បតិ
វេស្សន្តរេ វរំ ទត្វា សក្កកាយំ អបក្កមីតិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ភិក្ខវេ ម្នាលសង្ឃដ៏ខ្លាចភ័យក្នុងវដ្ដសង្សារ សក្កោ រី សម្ដេចព្រះឥន្ទ្រាធិរាជ សុត្វា ព្រះអង្គបានស្ដាប់ព្រះរាជឱង្ការព្រះបរមពោធិសត្វ សូមព្រះពរបវរជាឧត្ដម ព្រះឥន្ទ្រាក៏ទ្រង់អភិរមសោមនស្សាទើបទ្រង់ទូលថា «បពិត្រព្រះអង្គដ៏ទ្រង់ព្រះរាជសម្ភារ ព្រះអង្គគង់ឱ្យជាសុខ កុំជាទុក្ខព្រួយព្រះរាជហឫទ័យ ពុំយូរឡើយនែ សម្ដេចព្រះវររាជបិតាក៏នឹងរលឹកដល់ព្រះអង្គ នឹងលើកចតុរង្គសេនាចេញមកឯភ្នំគិរីវង្កត អារាធនាឱ្យលាព្រតចេញពីឥសី ចូលទៅបុរីតាមដូចព្រះប្រាថ្នា អប្បមត្តា ចូរព្រះអង្គឧស្សាហ៍កុំប្រមាទ សង្វាតបំពេញព្រះកម្មដ្ឋាន ឱ្យបានប្រសើរទៅឯមុខ នឹងបានចម្លងសព្វសត្វ ទៅទុកដល់អម្រឹតបុរីស្រីមហានគរនិព្វាន ។ សម្ដេចព្រះឥន្ទ្រា ដ៏មានតេជះតបៈឫទ្ធី ឧត្វា លុះបានទ្រង់ប្រទានព្រះពរទាំង ៨ ប្រការ ថ្វាយព្រះបរមក្សត្រា ព្រះមហាវេស្សន្តរបវររាជឥសី ជាបរិបូណ៌ស្រេចហើយ អបក្កាមិ ក៏ស្ដេចឡើងទៅកាន់វិមានពេជយ័ន្តជាឋានរបស់ព្រះអង្គ នាកាលនោះឯងហោង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

សត្ថុបត្ថំ និដ្ឋិតំ បពិត្រអើយ អាត្មាភាពសម្ដែងថ្លែងព្រះធម៌វិសេសទេសនាកណ្ឌសក្កបព្វ ដ៏ប្រដាប់នូវព្រះគាថាទាំងឡាយ ៤៣ គាថា ឲ្យ ក៏ចប់បរិបូណ៌ ដោយសមគួរនៅវេលានេះឯងហោង។

(ចប់កណ្ឌសក្កបព្វ ទី ១០ តែប៉ុណ្ណោះ)

---

វាយខំព្យូទ័រសាឡើងវិញ

ដោយ

**ភិក្ខុ កិច្ចភិរតោ ឡាយ រិន**

និង

ត្រួតពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ

ដោយ

**លោកគ្រូ ធម្មនាថ ផនប្រសិទ្ធិ៍**

ដើម្បីផ្សព្វផ្សាយ ជូនជាធម្មទាន តាមរិបសាយ

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទានឈ្នះអស់ទានទាំងពួង


ញ៉ុក . ថែម
មហាវេស្សន្តរជាតក
កណ្ឌទី ១០
ព.ស ២៥៤៦ គ.ស ២០០២